

# ថ្ងៃទី ៩ តុលា ១៩៧០

**សេរីការ**

ថ្ងៃទី៩ តុលា ជាថ្ងៃកំណើតនៃការប្រកាសជាឧឡារិក **សាធារណរដ្ឋខ្មែរ**[1] ដើម្បីពង្រឹងការតស៊ូរបស់ប្រជាពលរដ្ឋខ្មែរ វាយកំចាត់នូវការឈ្លានពានពួកយួនកុម្មុយនិស្តមកក្នុងទឹកដីខ្មែរ។ កាលនោះ ការបង្កើត សាធារណរដ្ឋខ្មែរ គ្មានគោលការណ៍ បំបែកសាមគ្គីខ្មែរ នៅចំពោះមុខសត្រូវជាតិ មានរូបភាពពិតប្រាកដ គឺយួនកុម្មុយនិស្ត ដែលមាន រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិខ្មែរនៅក្រៅប្រទេស ដឹកនាំដោយ សម្តេច សីហនុ ជាជំនួយដល់យួនយៀកកុង[2] ក្នុងផ្នែកនយោបាយនិងរណសិរ្សបង្រួបបង្រួមជាតិខ្មែរ នៅក្នុងប្រទេស ដឹកនាំដោយ គណបក្សកុម្មុយនិស្តខ្មែរជាបរិវារ របស់យួនកុម្មុយនិស្ត ក្នុងផ្នែកយោធា។ ដូច្នេះ ការតស៊ូខ្មែរ នៅពេលនោះ ត្រូវចាំបាច់ ផ្គត់ផ្គង់ ដោយអង្គការនយោបាយមួយ ដែលអាចបញ្ជាក់ឲបានច្បាស់លាស់ អំពីខ្លឹមសារជាតិ នៅចំពោះមុខ សត្រូវជាតិ គឺ ទី១ ទ័ពបរទេសឈ្លានពាន ទី២ រាជរដ្ឋាភិបាលខុសច្បាប់និងក្បត់ជាតិខ្លួនឯងបំរើផលប្រយោជន៍សត្រូវជាតិ និង ទី៣ លទ្ធិកុម្មុយនិស្ត ដែលជា សត្រូវនឹង ពុទ្ធសាសនា និងសេរីភាព នៃប្រជាពលរដ្ឋខ្មែរ។ ដោយយល់ឃើញ អំពីត្រីគ្រោះថ្នាក់នោះឯង អ្នកដឹកនាំខ្មែរ

---

[1] សាធារណរដ្ឋខ្មែរ ប្រកាសនៅថ្ងៃទី ៩ តុលា ឆ្នាំ ១៩៧០។

[2] យួនយៀកកុង ជារណសិរ្ស របស់យួនកុម្មុយនិស្ត ដើម្បីវាយប្រហារយួនខាងត្បូង ដែលជាយួនសេរី។

ជំនាន់នោះ ក្រោយពីបានខំស្វែងរក នូវគ្រប់មធ្យោបាយ តែគ្មានផលជាវិជ្ជមាន នៃដំណោះស្រាយតាមសន្តិវិធី ជាមួយប្រតិបក្ស រៀបរាប់ឈ្មោះខាងលើនោះ បានជ្រើសរើសយករបបសាធារណរដ្ឋ ជាកំផែង សំរាប់ការពារជាតិ និងពុទ្ធសាសនា ជាកម្លាំងតស៊ូជាតិ និង ជាផ្លូវអនាគត សំរាប់កសាងប្រទេសឲទាន់សម័យ ព្រោះ របបនោះ វាឆ្លើយតបពិតប្រាកដនឹង សេចក្តីប្រាថ្នា របស់ប្រជាពលរដ្ឋ ជាពិសេស យុវជន និងបញ្ញវន្តដែលស្រេក នូវសេរីភាព ព្រោះប្រជារាស្ត្រ រស់នៅក្រោមរបបសក្តិភូមិ រយឆ្នាំ និង អំណាចផ្តាច់ការ របស់ សម្តេច សីហនុ បីទស្សវត្សរ៏ មកហើយ។

ផ្តត់ផ្គង់ ដោយការគាំទ្រ ពីសំណាក់ប្រជាពលរដ្ឋ និងបានបង្ហាញឲឃើញ នូវទស្សនវិស័យ នៃអនាគតថ្លៃថ្លា សំរាប់ជាតិការណ៏នេះ ដែលអាចឲ សាធារណរដ្ឋខ្មែរ បង្កើតបាន នូវកម្លាំងស្មារតីជាតិជិតដល់ សំរាប់ប្រឆាំងនឹង ការឈ្លានពានរបស់យួនកុម្មុយនិស្ត។ ក្នុងរយៈពេល៥ឆ្នាំ នៃអាយុជីវិតរបស់សាធារណរដ្ឋខ្មែរ កងទ័ពជាតិខ្មែរ កើតចេញពីកម្លាំងប្រជាពលរដ្ឋ វាយប្រហារទប់ទល់យ៉ាងអង់អាចនឹង ទ័ពយួនកុម្មុយនិស្ត នៅគ្រប់សមរភូមិ ទោះបីមានកង្វះអាវុធយុទ្ធភ័ណ្ឌ និងចំនួនយោធិនដែលត្រូវមានជាចាំបាច់ សំរាប់ធ្វើសង្គ្រាមការពារដែនដី និងការពារសន្តិសុខដល់ប្រជាពលរដ្ឋ។ ត្រូវដឹងថា ជំនួយយោធាដែលសាធារណរដ្ឋបានទទួលពីសហរដ្ឋអាមេរិក មានកំរិតទាបបំផុត បើយកវា មកប្រៀបធៀបនឹងជំនួយយោធា ដែលយួន

កុម្មុយនិស្ត បានទទួលពីលោកកុម្មុយនិស្ត សំរាប់ធ្វើសង្គ្រាម នៅស្រុកខ្មែរ និងយួនខាងត្បូងបានទទួល ពីសហរដ្ឋអាមេរិក សំរាប់ច្បាំងនៅស្រុកយួន។ ត្រូវដឹងថាសង្គ្រាមនៅស្រុកខ្មែរនិង នៅស្រុកយួនខាងត្បូង មានសភាពខុសគ្នាឆ្ងាយណាស់ ចំពោះ សហរដ្ឋអាមេរិក ព្រោះនៅស្រុកយួន អាមេរិកាំង ធ្វើសង្គ្រាម ផ្ទាល់ ដើម្បីជួយទ័ពយួនខាងត្បូង ដែលជាសម្ពន្ធមិត្តនឹងខ្លួន ចំណែកនៅស្រុកខ្មែរ គឺទ័ពខ្មែរ តែម្នាក់ឯង ធ្វើសង្គ្រាមប្រឆាំង នឹង ការឈ្លានពានរបស់យួនកុម្មុយនិស្ត ទោះបីទ័ពខ្មែរ មាន ជំនួយម្តងៗ ពីសំណាក់ទ័ពយួនខាងត្បូង និងទ័ពអាកាសអា មេរិកាំងក៏ដោយ តែជំនួយនោះមិនមានគោលដៅពិតប្រាកដ ជួយទ័ពខ្មែរនោះឡើយ វាគ្រាន់តែជាជំនួយ នៅក្នុងយុទ្ធសាស្ត្រ សង្គ្រាមអាមេរិកាំង នៅវៀតណាមតែប៉ុណ្ណោះ។ នៅពេលនោះ យុទ្ធសាស្ត្រសង្គ្រាមអាមេរិកាំង គឺគ្មានគោលដៅ ជួយខ្មែរ ដេញ ទ័ពយួនកុម្មុយនិស្ត ពីស្រុកខ្មែរនោះឡើយ គឺគ្រាន់តែចៀសកុំឲ ទ័ពខ្មាំង ពង្រឹងមូលដ្ឋានសឹកនៅស្រុកខ្មែរ សំរាប់វាយទ័ពអា មេរិកាំង និងយួនខាងត្បូង នៅស្រុកយួនតែប៉ុណ្ណោះ។ មួយវិញ ទៀត សហរដ្ឋអាមេរិក កំពុងចរចាជាសម្ងាត់ ជាមួយយួន កុម្មុយនិស្ត ដើម្បីដកទ័ពខ្លួនចេញពីវៀតណាម ដូច្នេះ ជួយ សាធារណរដ្ឋខ្មែរ ប្រឆាំងនឹងយួនកុម្មុយនិស្ត វាជាការរំខានទៅ វិញ ដល់ការចរចា ជាមួយចិនកុម្មុយនិស្ត ដែលជា អ្នកគាំទ្រ ចេញមុខដល់ រាជរដ្ឋាភិបាលនៅក្រៅស្រុករបស់សម្តេចសីហនុ និងយួនកុម្មុយនិស្ត។

កិច្ចព្រមព្រៀងសន្តិភាព នៅឆ្នាំ១៩៧៣ រវាងអាមេរិកាំង នឹងយួនកុម្មុយនិស្ត អាចចាត់ទុកបានជា ការបោះបង់ចោលឥណ្ឌូចិន ដោយសហរដ្ឋអាមេរិក ប្រគល់ឲទៅចិន និងយួនកុម្មុយនិស្ត ក្នុងគោលដៅតែមួយគត់ គឺ សង្គ្រោះកិត្តិយសអាមេរិកាំង។ ត្រូវដឹងថា ក្រោយពីចុះហត្ថលេខា កិច្ចព្រមព្រៀងសន្តិភាពនោះមក សហរដ្ឋអាមេរិក មិនត្រឹមតែកាត់ជំនួយយោធាផ្តល់ឲសាធារណរដ្ឋខ្មែរ និងយួនខាងត្បូងតែប៉ុណ្ណោះទេ គឺថែមទាំង កាត់ជំនួយសេដ្ឋកិច្ច ដែលមិនអាចឲប្រទេសទាំងពីរ មានលទ្ធភាពបន្តការតស៊ូប្រឆាំងនឹង យួន និងខ្មែរកុម្មុយនិស្ត ដែលពួកវានៅតែ ទទួលជំនួយបន្ថែមពីលោកកុម្មុយនិស្ត ដើម្បីបន្តសង្គ្រាម យកជ័យជំនះតាមផ្លូវយោធា ដែលផ្ទុយស្រឡះពីស្មារតីកិច្ចព្រមព្រៀងសន្តិភាព។ សាធារណរដ្ឋខ្មែរ នៅពេលនោះ គ្មានការតឹងរ៉ឹងអ្វី ប្រឆាំងនឹងកិច្ចព្រមព្រៀងសន្តិភាពនោះឡើយ គឺសុំតែឲ សហរដ្ឋអាមេរិក ជួយបញ្ឈប់សង្គ្រាម កុំឲមានសោគនាដកម្មកុម្មុយនិស្ត កើតមានឡើងក្រោយបញ្ឈប់សង្គ្រាម។ ចំពោះ សហរដ្ឋអាមេរិក ដែលជាមហាអំណាចលេខ១ ក្នុងពិភពលោក ទុកសំណើរបស់ខ្មែរ ដូចទម្ងន់មួយខ្លាំណាស់ គឺមិនត្រឹមតែ យ៉ាងហោចណាស់ ជួយលើកទឹកចិត្តការតស៊ូខ្មែរ ប្រឆាំងនឹងកុម្មុយនិស្ត ដើម្បីសេរីភាព គឺថែមទាំងបិទស្ថានទូត បោះបង់ ប្រជាពលរដ្ឋខ្មែរ ដែលមានជំនឿលើអាមេរិកាំង ព្រោះទុកជាមហាប្រទេសនៃសេរីភាពនិងលទ្ធិប្រជាធិបតេយ្យ។ ទង្វើអាមេរិកាំងនោះ ហាក់បីដូចជាគ្មានក្តីបារម្ភបន្តិចបន្តួចសោះនោះឡើយ ដល់ផលវិបាក ជាវិនាដកម្ម

ដែលរបបកុម្មុយនិស្តធ្លាប់បានប្រព្រឹត្តជានិច្ចនៅពេលដែល ខ្លួនមានជ័យជំនះ។

ចំពោះ អ្នកសាធារណរដ្ឋនិយម លោកទុក ថ្ងៃទី៩ តុលា ជានិមិត្តរូប នៃសេរីភាព និងការតស៊ូប្រឆាំងនឹង យួនកុម្មុយនិស្តជាអ្នកឈ្លានពានទឹកដីខ្មែរ។ សាធារណរដ្ឋខ្មែរ ស្លាប់រូបពិត តែព្រលឹងនៅគង់វង់ជានិច្ច សំរាប់កូនខ្មែរ ដែលនៅមានទឹកចិត្តតស៊ូប្រឆាំងនឹង អាណានិគមយួនកុម្មុយនិស្តនៅស្រុកខ្មែរសព្វថ្ងៃ។ សាធារណរដ្ឋខ្មែរ មិនមែនស្លាប់រូប ដោយចាញ់សង្គ្រាមនឹងយួនកុម្មុយនិស្ត នោះឡើយ តែបាត់រូប ក្នុងស្មារតី បង្រួបបង្រួមជាតិ ដូចគ្នានឹង ថ្ងៃកំណើតរបស់ខ្លួននោះដែរ តែពួកខ្មែរក្រហម ក្បត់ជាតិខ្លួនឯង មិនព្រមប្រគប់កម្លាំងជាតិ បែរជា យកលទ្ធិកុម្មុយនិស្ត មកដាក់លើប្រយោជន៍ជាតិ សម្លាប់ខ្មែរគ្នាឯង បំផ្លាញកម្លាំងប្រជាជាតិ ដែលនាំឲ យួន ឆ្លៀតឱកាស វាយបែកកងទ័ពការពារជាតិ យកស្រុកខ្មែរ ដាក់ជាប្រទេសចំណុះ។ ត្រូវដឹងថា សព្វថ្ងៃនេះ ពួកខ្មែរក្រហមនោះឯងជាអ្នកជួយយួន ឲវាលេបស្រុកខ្មែរចូលទៅក្នុងពោះវា។ តែខ្មែរត្រូវមានជំនឿថា យួន អាចលេបស្រុកខ្មែរបាន តែច្បាស់ជាក្រពះយួន មិនអាចរំលាយប្រជាជាតិខ្មែរ ដូចរំលាយអាហារបានងាយនោះឡើយ បើខ្មែរ នៅមានស្មារតីតស៊ូជានិច្ច ហើយគ្មានសន្ទិះ (ការសង្ស័យ) ទៅលើកម្លាំងជាតិខ្លួន៕